ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

# ការណែនាំ

## ស្តីពី

# ការអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន

## សំរាប់

# សាលារៀន សហគមន៍ និង អង្គការក្រៅរដ្ឋាភិបាល

ផ្សាយចេញពីនាយកដ្ឋានស្រាវជ្រាវគរុកោសល្យ

គំរោង CBE ឆ្នាំ២០០៦

# កថាមុខ

ការអប់រំបំណិនជីវិត ផ្តល់សារៈសំខាន់ពីរយ៉ាង គឺផ្នែកសុខុមាលភាពផ្ទាល់ខ្លួនរបស់សិស្សានុសិស្ស និងផ្នែកសមត្ថភាពរបស់ពួកគេ ក្នុងការរួមចំណែកអភិវឌ្ឍប្រទេសជាតិ ។

ឯកសារណែនាំសំរាប់ការអនុវត្តកម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋាននេះ ត្រូវបានអភិវឌ្ឍឡើងសំរាប់ជាជំនួយដល់អ្នកពាក់ព័ន្ធទាំងឡាយ ដើម្បីឱ្យអនុវត្តកម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋាន នៃគោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សា ២០០៥-២០០៩ ។

ឯកសារណែនាំសំរាប់ការអនុវត្តកម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋាន ជាឯកសារសំខាន់មួយ ជួយដល់អ្នកពាក់ព័ន្ធទាំងឡាយ ក្នុងការបញ្ចូលកម្មវិធីនេះបន្ថែមទៅក្នុងកម្មវិធីសិក្សាគោល ។

ឯកសារណែនាំសំរាប់ការអនុវត្តកម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋាន បានបង្ហាញពីលំនាំ ដែលសាលារៀន សហគមន៍ និងអង្គការក្រៅរដ្ឋាភិបាល ត្រូវធ្វើការរួមគ្នាដើម្បីអភិវឌ្ឍកម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋានប្រកបដោយប្រសិទ្ធភាព ។

ក្រសួងអប់រំ យុវជន និងកីឡា សូមអំពាវនាវដល់អ្នកពាក់ព័ន្ធទាំងឡាយ សូមខិតខំប្រឹងប្រែង ព្យាយាមអនុវត្តឱ្យបាននូវឯកសារនេះ ទៅតាមតួនាទី និងភារកិច្ចរៀង១ខ្លួន ។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមថា សហគមន៍មូលដ្ឋាន អង្គការជាតិ និងអន្តរជាតិ នឹងបន្តជួយជំរុញការកែលំអគុណភាពអប់រំនៅកម្ពុជា ឱ្យសម្រេចជោគជ័យទៅតាមគោលនយោបាយនៃរាជរដ្ឋាភិបាលកម្ពុជា ។

ឯកសារណែនាំសំរាប់ការអនុវត្តកម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋាននេះ នឹងចូលជាធរមានចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ហើយក្រសួងអប់រំ យុវជន និងកីឡា សូមប្រកាសឱ្យប្រើប្រាស់ឯកសារនេះជាផ្លូវការចាប់ពីពេលនេះតទៅ។

ភ្នំពេញ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិត គុល ផេង**

# សេចក្តីផ្តើម

*គោលនយោបាយថ្មីសំរាប់អនុវត្តន៍កម្មវិធីសិក្សា* និង *គោលនយោបាយអប់រំបំណិនជីវិតតាមមូលដ្ឋាន* មានចែងពីចក្ខុវិស័យ និងផែនការនៃការផ្តល់សេវាអប់រំបំណិនជីវិតតាមមូលដ្ឋាន របស់ក្រសួងអប់រំ យុវជន និងកីឡា។

សមាសភាពនៃការផ្តល់សេវាអប់រំបំណិនជីវិតតាមមូលដ្ឋាន គឺជាការអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋានថ្មី ដែលសាលារៀនត្រូវបង្រៀនកម្មវិធីថ្មីនេះ ពី២-៥ ម៉ោង ក្នុងមួយសប្តាហ៍។ កម្មវិធីនេះជាកម្មវិធីដែលត្រូវបានអភិវឌ្ឍឡើង ដើម្បីបង្កើនភាពទាក់ទងទៅនឹងស្ថានភាពតាមតំបន់ ដោយផ្តល់ឱកាសដល់សិស្សក្នុងការពង្រីកចំណេះដឹងបន្ថែម ដែលនេះជាផ្នែកមួយនៃកម្មវិធីសិក្សាក្នុងប្រព័ន្ធតាមសាលារៀន។ កម្មវិធីនេះផ្តល់នូវបំណិនវិជ្ជាជីវៈ និងបុរេវិជ្ជាជីវៈ ដែលស្របទៅនឹងស្ថានភាពជាក់ស្តែងនៅតាមមូលដ្ឋាន និងអភិវឌ្ឍបំណិនជីវិតតាមជំរើសរបស់សិស្ស។

**កម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋានមិនមានលក្ខណៈដូចគ្នាទាំងអស់ទេ** ប៉ុន្តែ កម្មវិធីនេះមានធនធាន និងពេលវេលាសំរាប់ឱ្យសាលារៀន និងសហគមន៍អាចធ្វើការសំរេចប្រើប្រាស់ យ៉ាងណាឱ្យ មានលក្ខណៈល្អប្រសើរបំផុត សមស្របតាមតំរូវការជាក់ស្តែងរបស់សិស្ស។

គេរំពឹងទុកថា សកម្មភាពនៃកម្មវិធីបំណិនជីវិតតាមមូលដ្ឋាននឹងមានសារប្រយោជន៍ អាចជួយបង្កើនចំណាប់អារម្មណ៍ ធ្វើឱ្យសិស្សរីករាយក្នុងការសិក្សា និងជួយឱ្យសិស្សធ្វើសកម្មភាពយ៉ាងសកម្ម។

ឯកសារណែនាំនេះ ត្រូវបានរៀបចំឡើងជាឯកសារជំនួយដល់សាលារៀន សហគមន៍ និងអង្គការក្រៅរដ្ឋាភិបាល ក្នុងការបង្កើតកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ដើម្បីយកទៅបង្រៀននៅតាមសាលារៀន។

ការផ្តល់កម្មវិធីបំណិនជីវិតតាមមូលដ្ឋានដែលបានរៀបចំនៅក្នុងឯកសារនេះ មានបីរបៀប ដូចខាងក្រោម:

១. ភាពជាដៃគូ រវាងសាលារៀន និងអង្គការក្រៅរដ្ឋាភិបាល

២. ភាពជាដៃគូ រវាងសាលារៀន និងសហគមន៍

៣. កម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ដែលរៀបចំឡើងដោយសិស្ស

## ជំរើសទី១: ភាពជាដៃគូ រវាងសាលារៀន និងអង្គការក្រៅរដ្ឋាភិបាល

អង្គការក្រៅរដ្ឋាភិបាលជាច្រើនមានការចាប់អារម្មណ៍លើកម្មវិធីបំណិនជីវិត ហើយកំពុងតែផ្តល់ការគាំទ្រកម្មវិធីបំណិនជីវិត។ សាលារៀនអាចធ្វើទំនាក់ទំនងជាមួយនឹងអង្គការក្រៅរដ្ឋាភិបាល នៅតាមមូលដ្ឋាន និងអាចស្នើសុំការជួយឧបត្ថម្ភគាំទ្រពីអង្គការទាំងនោះ ដើម្បីបង្កើតកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន។

អង្គការក្រៅរដ្ឋាភិបាលដែលមានបំណងចង់សហការជាមួយនឹងសាលារៀន ក្នុងការផ្តល់កម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ត្រូវធ្វើការចុះបញ្ជីកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន នៅក្នុងឯកសារណែនាំនេះ ផ្នែកខាងចុង។

សាលារៀន និងអង្គការក្រៅរដ្ឋាភិបាលត្រូវសហការគ្នា បំពេញទំរង់ពាក្យសុំចុះបញ្ជីរួមគ្នា។ ការចុះបញ្ជីនេះនឹងជួយឱ្យសាលារៀន និងអង្គការក្រៅរដ្ឋាភិបាលធ្វើការសំរេចចិត្តបានត្រឹមត្រូវ ក្នុងដំណើរការកម្មវិធី។

## ជំរើសទី២: ភាពជាដៃគូ រវាងសាលារៀន និងសហគមន៍

នេះគឺជាកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ដែលសមាជិកស្ម័គ្រចិត្តរបស់សហគមន៍អាចផ្តល់ឱ្យ។

ឧទាហរណ៍នៃកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ចំនួន២០ខាងក្រោម ត្រូវបានរៀបចំឡើង ដើម្បីផ្តល់ពត៌មានសំខាន់ៗចាំបាច់សំរាប់អ្នកស្ម័គ្រចិត្តរបស់សហគមន៍ ក្នុងការដំណើរការកម្មវិធី ស្របទៅតាមធនធានដែលមាន។

ប្រធានបទចំនួន២០ ដូចខាងក្រោម ជាឧទាហរណ៍:

| | |
|---|---|
| ១- ការប៉ះកង់ | ១១- ការធ្វើទ្រុងសត្វល្អិត |
| ២- ការសង្គ្រោះបឋម | ១២- ការដេរប៉ាក់ |
| ៣- ការយល់ដឹងពីសុវត្ថិភាពចរាចរណ៍ | ១៣- ការដេរសំពត់ |
| ៤- ការថែទាំទោចក្រយានយន្ត | ១៤- ការថែរក្សាបរិស្ថាន |
| ៥- ការបង្កើតទីផ្សារលក់ផលិតផលរបស់សិស្ស | ១៥- ការធ្វើខ្លែង |
| ៦- ការធ្វើសួនបន្លែក្នុងសាលារៀន | ១៦- ការរៀបចំសំដែងសិល្បៈ |
| ៧- ការដាំផ្សិតចំបើង | ១៧- ការធ្វើម្ហូប |
| ៨- ការធ្វើឆ្នាំង/ក្អម | ១៨- ការរៀបចំកម្មវិធីប្រកួតកីឡាបាល់ទះ |
| ៩- ការធ្វើកញ្ច្រែងឫស្សី | ១៩- ការថែរក្សាទារក |
| ១០- លំហាត់ប្រាណ និងកម្មវិធីកីឡា | ២០-ការយល់ដឹងអំពីពិការភាព |

ឯកសារស្តីពីបំណិនជីវិតនេះ ត្រូវបានថតចំលង និងចែកជូនដល់គ្រប់សាលារៀនទាំងអស់ ចំនួន២០ច្បាប់ រួមជាមួយនឹងឯកសារណែនាំនេះ ផងដែរ។

សាលារៀនអាចសហការជាមួយនឹងសមាជិកសហគមន៍ ដើម្បីផ្តល់ឧទាហរណ៍គំរូមួយ ឬ លើសពីនេះ ដោយអនុវត្តតាមដំណាក់ការដូចខាងក្រោម:

| | |
|---|---|
| ដំណាក់ការទី១ | អញ្ជើញមាតាបិតា និងសហគមន៍មកចូលរួមប្រជុំពិភាក្សា និងស្វែងយល់អំពីកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន និងធ្វើការសំរេចជ្រើសរើសកម្មវិធី ព្រមទាំងធ្វើការកំណត់ និងជ្រើសរើសគ្រូសហគមន៍ ដើម្បីធ្វើការបង្រៀន។ ទិសដៅនៃកម្មវិធីបំណិនជីវិត និងរបៀបវាយតំលៃលើជោគជ័យនៃកម្មវិធីនេះ គឺអង្គប្រជុំជាអ្នកកំណត់។ |
| ដំណាក់ការទី២ | កំណត់ពេលវេលាច្បាស់លាស់ក្នុងមួយសប្តាហ៍ នៅពេលផ្តល់សេវាកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន។ |
| ដំណាក់ការទី៣ | កំណត់ចំនួនវគ្គដែលត្រូវបង្រៀននៅក្នុងកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន (ឧ. មួយវគ្គសំរាប់មួយ ឬពីរសប្តាហ៍ ឬបួនសប្តាហ៍ ឬ រយៈពេលវែងជាងនេះ)។ |
| ដំណាក់ការទី៤ | កំណត់ទីកន្លែងសមស្របសំរាប់ដំណើរការកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន។ |
| ដំណាក់ការទី៥ | មុនពេលចាប់ផ្តើមដំណើរការកម្មវិធី នាយកសាលាត្រូវជួបប្រជុំជាមួយនឹងគ្រូសហគមន៍ ដើម្បីកំណត់ជ្រើសរើសធនធានសំភារៈសំរាប់ដំណើរការ និងរបៀបផ្តល់កម្មវិធីនេះ។ |
| ដំណាក់ការទី៦ | នាយកសាលាត្រូវពិនិត្យមើលកម្មវិធីដែលបានជ្រើសរើស ជាមួយនឹងគ្រូសហគមន៍ ដើម្បីធានាឱ្យមានការអនុវត្តត្រឹមត្រូវតាមដំណាក់ការច្បាស់លាស់។ |
| ដំណាក់ការទី៧ | សិស្សនឹងត្រូវបានជ្រើសរើសឱ្យចូលរៀនក្នុងកម្មវិធីនេះ ទៅតាមកំរិតថ្នាក់។ |
| ដំណាក់ការទី៨ | ពេលកម្មវិធីនេះដំណើរការ ការវាយតំលៃនឹងត្រូវធ្វើឡើង ដើម្បីកែលំអចំណុចខ្វះខាត។ |

**ជំរើសទី៣: កម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ដែលរៀបចំឡើងដោយសិស្ស**

គោលវិធីសិស្សមជ្ឈមណ្ឌលនឹងត្រូវបានយកមកប្រើនៅក្នុងជំរើសនេះ។ ការជំរុញឱ្យសិស្សរួមចំណែកយ៉ាងសកម្មនៅក្នុងការរៀបចំកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន គឺជាមធ្យោបាយមួយដ៏ល្អប្រសើរ និងធានាឱ្យកម្មវិធីនេះមានភាពផ្សារភ្ជាប់ទៅនឹងតំរូវការជាក់ស្តែង និងត្រូវនឹងចំណាប់អារម្មណ៍របស់សិស្ស ហើយក៏ជាមធ្យោបាយមួយដ៏មានប្រសិទ្ធភាពក្នុងការអភិវឌ្ឍបំណិនជីវិតរបស់សិស្ស។ ក្នុងករណីដែលសិស្សរៀបចំកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន នោះសិស្សអាចរៀនអំពីបំណិនសិក្សា បំណិនគ្រប់គ្រង បំណិនគិតគូរ បំណិនវាយតំលៃ និងបំណិនធ្វើសេចក្តីសំរេច ដោយខ្លួនឯង។

| | |
|---|---|
| ដំណាក់ការទី១ | **ការផ្សព្វផ្សាយពត៌មានអំពីកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន**<br>គ្រូបង្រៀន សមាជិកគណៈកម្មាធិការសាលារៀន និងនាយកសាលាត្រូវជួបប្រជុំ ពិភាក្សា និងសិក្សាស្វែងយល់អំពីកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន និងដើម្បីធ្វើការសំរបសំរួល និងរៀបចំផែនការសំរាប់បង្កើតកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ដែលសិស្សជាអ្នកចូលរួមចំណែក។<br>• អង្គប្រជុំនេះត្រូវធ្វើឡើងប្រចាំសប្តាហ៍ ដើម្បីពិភាក្សាអំពីការបង្កើតកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ព្រមទាំងកំណត់រយៈពេលបង្រៀន (ឧ. ៨ ទៅ ១២ សប្តាហ៍)។ |

| | |
|---|---|
| | • អង្គប្រជុំត្រូវសំរេចថា តើសាលារៀនណាខ្លះដែលមានថវិកា ដើម្បីយកមកប្រើប្រាស់សំរាប់កម្មវិធី ដូចជាការទិញធនធានសំភារៈ និងការចំណាយលើសមាជិកសហគមន៍ដែលនឹងមកបង្រៀនជំនាញ។ បើសិនជាពុំមានថវិកាទេ កម្មវិធីនេះត្រូវពឹងផ្អែកទៅលើធនធានតាមមូលដ្ឋាន ធនធានសំភារៈរបស់ជំនួយ និងម៉ោងពេលរបស់គ្រូសហគមន៍ ដែលត្រូវបង្រៀន។<br>• សំរេចថា តើសកម្មភាពទាំងនេះនឹងត្រូវអនុវត្តនៅទីកន្លែងណា។ តើសាលារៀនត្រូវត្រួតពិនិត្យសកម្មភាពទាំងនេះ ដោយរបៀបណា។<br>• ពិភាក្សាពីទិសដៅនៃកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន និងសំរេចពីរបៀបវាយតំលៃលើជោគជ័យនៃកម្មវិធី។<br>• គ្រូបង្រៀនគ្រប់រូបត្រូវបើកអង្គប្រជុំជាមួយសិស្សតាមថ្នាក់រៀន ដើម្បីណែនាំពន្យល់សិស្សអំពីកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន និងជួយសិស្សក្នុងការរៀបចំផែនការស្រាវជ្រាវ និងចាត់ចែងឱ្យសិស្សចុះអនុវត្ត។ |
| **ដំណាក់ការទី២** | **សិស្សធ្វើការស្រាវជ្រាវ**<br>សិស្សធ្វើការស្រាវជ្រាវនៅក្នុងសហគមន៍ ដើម្បីឆ្លើយសំនួរពីរខាងក្រោម៖<br>• តើនៅក្នុងសហគមន៍របស់យើងមានមុខរបរ និងអ្នកជំនាញអ្វីខ្លះ?<br>• តើអ្នកណាខ្លះនៅក្នុងសហគមន៍របស់យើងមានបំណិនទាំងនេះ ហើយអាចបណ្តុះបណ្តាលអ្នកដទៃបាន? |
| **ដំណាក់ការទី៣** | **ដំណើរការប្រមូលទិន្នន័យស្រាវជ្រាវ**<br>• ទិន្នន័យស្រាវជ្រាវ ដែលជាលទ្ធផលនៃការស្រាវជ្រាវរបស់សិស្សក្នុងថ្នាក់រៀន ទាំងមូល នឹងត្រូវប្រមូលផ្តុំ ចងក្រងឡើងទៅតាមកំរិតថ្នាក់។<br>• គ្រូបង្រៀនត្រូវធ្វើការសំរបសំរួល និងលើកទឹកចិត្តដល់សិស្សក្នុងការធ្វើសេចក្តីសំរេចជ្រើសរើសវិធីសាស្ត្រណាដែលល្អប្រសើរ ដើម្បីដំណើរការ។<br>• សួរសិស្សថា តើបំណិនទាំងអស់នៅក្នុងបញ្ជីនេះអាចយកមកអនុវត្តនៅក្នុងបរិបទកម្មវិធីបំណិនជីវិតតាមមូលដ្ឋានដែរឬទេ។ ធ្វើការពិភាក្សា និងដកបំណិនណាមួយ ដែលពុំមានលក្ខណៈសមស្របចេញ។ ពន្យល់សិស្សថា សកម្មភាពនីមួយៗត្រូវ៖<br>○ មានលក្ខណៈស្របទៅតាមអាយុរបស់សិស្ស<br>○ មានសុវត្ថិភាព ដោយពុំតំរូវឱ្យមានការត្រួតពិនិត្យម៉ត់ចត់<br>○ មានលក្ខណៈសមស្រប ហើយអាចអនុវត្តទៅតាមធនធានដែលមាន<br>○ ឱ្យសិស្សអនុវត្ត យ៉ាងតិច ៥ នាក់ ដោយស្របតាមចំណាប់អារម្មណ៍របស់សិស្ស |

៦

| | |
|---|---|
| | ○ គំរូឱ្យមានអ្នកណាម្នាក់នៅក្នុងសហគមន៍ដែលមានបំណិននេះនិងមានឆន្ទៈក្នុងការបង្រៀន ។<br>• នៅតាមកំរិតថ្នាក់នីមួយៗ សិស្សត្រូវកត់ត្រាបំណិនដែលបានលើកឡើងនៅក្នុងជំរើសទី១ ជំរើសទី២ និងជំរើសទី៣ បន្ទាប់មកត្រូវរៀបបំណិននេះទៅតាមក្រុម ដោយផ្អែកទៅលើបំណិនដែលខ្លួនជ្រើសរើស ដើម្បីសិក្សាតាមចំណង់ចំណូលចិត្តរបស់ខ្លួន ។<br>• បន្ទាប់មក ត្រូវធ្វើបញ្ជីឈ្មោះរបស់គ្រូសហគមន៍ ដែលនឹងត្រូវមកបង្រៀនបំណិន នេះទៅតាមក្រុមនីមួយៗ ។ |
| **ដំណាក់ការទី៤** | **ការចែករំលែក និងការផ្តល់ពត៌មានឡើងវិញ តាមថ្នាក់**<br>នៅចុងដំណាក់ការនេះ គ្រូបង្រៀនត្រូវឱ្យសិស្សរៀបចំជាក្រុម ទៅតាមបំណិនដែលសិស្សចង់សិក្សា មិនមែនតាមកំរិតថ្នាក់ឡើយ ។<br>• ក្រុមនីមួយៗត្រូវមានបញ្ជីគ្រូសហគមន៍ ដែលអាចបង្រៀនបំណិនដែលសិស្សជ្រើសរើស តាមការឯកភាព ។<br>• ក្រុមសិស្សនីមួយៗត្រូវមានសមាជិកក្រុមចាប់ពី៥នាក់ឡើងទៅ ប៉ុន្តែមិនលើសពី១០នាក់ ។<br>• បើក្រុមសិស្សមួយចំនួនពុំមានគ្រូសហគមន៍បង្រៀនបំណិនជំរើសទី១នោះទេ ត្រូវចូលរៀនជាមួយនឹងក្រុមបំណិនជំរើសទី២ ។<br>• ករណីក្រុមសិស្សមួយចំនួន មានសមាជិកតិចជាង៥នាក់ ត្រូវបញ្ចូលសិស្សទាំងនេះទៅក្នុងក្រុមបំណិនជំរើសទី២ ។<br>• ករណីក្រុមសិស្សមួយចំនួនមានសមាជិកលើសពី១០ នាក់ ត្រូវបំបែកជាក្រុមតូចៗ ដែលមានចំនួនលើសពី៥នាក់ និងតិចជាង១០នាក់ ។ (ក្រុមទាំងនេះមានបញ្ជីឈ្មោះគ្រូឧទ្ទេសសហគមន៍ដូចគ្នា ប៉ុន្តែ ក្រុមនីមួយៗត្រូវមានគ្រូឧទ្ទេសម្នាក់ ជាចាំបាច់) ។ |
| **ដំណាក់ការទី៥** | **ការលើកទឹកចិត្តគ្រូសហគមន៍ ដើម្បីបង្រៀនសិស្សតាមបំណិនដែលបានជ្រើសរើស**<br>• សិស្ស និងគ្រូបង្រៀនត្រូវទៅអញ្ជើញគ្រូសហគមន៍ដើម្បីឱ្យចូលរួមចំណែកក្នុងការបង្រៀនបំណិនក្នុងកម្មវិធីបំណិនជីវិតតាមមូលដ្ឋានតាមសាលារៀន ។ ត្រូវធានាឱ្យមានការផ្តល់ពត៌មានសមស្របដូចខាងក្រោម ដល់គ្រូសហគមន៍គ្រប់រូប ដើម្បីឱ្យគ្រូសហគមន៍ងាយស្រួលក្នុងការសំរេចចិត្តៈ<br>○ បំណិនណាមួយដែលសិស្សចង់រៀន<br>○ ចំនួនសិស្សក្នុងក្រុម<br>○ ពេលវេលា ទីកន្លែង ចំនួនសប្តាហ៍ ដែលត្រូវបង្រៀន |

| | |
|---|---|
| | ○ គ្រូសហគមន៍គួរដឹងថា សាលាអញ្ជើញពួកគាត់ឱ្យមកបង្រៀនតាមបំណិនរបស់ខ្លួន (ហើយសាលានឹងជូនប្រាក់កំរៃសំរាប់ការបង្រៀននេះ តាមធនធាន ដែលសាលាមាន)។<br>• សមាជិកសហគមន៍ដែលបានឯកភាពគាំទ្រកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន នឹងត្រូវបានអញ្ជើញឱ្យមកចូលរួមក្នុងអង្គប្រជុំ ដើម្បីទទួលការណែនាំ និងបានជ្រួតជ្រាបអំពីកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន។ |
| **ដំណាក់ការទី៦** | **កិច្ចប្រជុំគ្រូសហគមន៍ ជាអ្នកដែលបានឯកភាពបង្រៀនតាមបំណិនរបស់ខ្លួន**<br>• មាតាបិតាសិស្សដែលមានការចាប់អារម្មណ៍អាចអញ្ជើញចូលរួមនៅក្នុងអង្គប្រជុំនេះបាន។<br>• ផ្ដល់ពត៌មានសាវតារស្ដីពីៈ<br>○ ទិសដៅនៃសកម្មភាពកម្មវិធីបំណិនជីវិតតាមមូលដ្ឋានដែលពាក់ព័ន្ធទៅនឹងសិស្ស។<br>○ របៀបរៀបចំកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន។<br>○ សារៈសំខាន់នៃការចូលរួមយ៉ាងកម្មរបស់សិស្សក្នុងការសិក្សា<br>○ ការរំពឹងទុករបស់គ្រូសហគមន៍ក្នុងដំណើរការកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន។<br>• ជួយសំរបសំរួល ជំរុញ និងលើកទឹកចិត្តដល់គ្រូសហគមន៍គ្រប់រូប ដើម្បីឱ្យពួកគេគាំទ្រកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន យ៉ាងប្តូរផ្តាច់ ស្របទៅតាមទិសដៅ ដែលចង់បាន។<br>• ជួយសំរបសំរួលដល់គ្រូសហគមន៍ក្នុងការធ្វើការបែងចែកបំណិន ដែលពួកគេចង់បង្រៀន ទៅតាមចំនួនសប្តាហ៍នៃកម្មវិធីបំណិនជីវិតតាមមូលដ្ឋានដែលបានកំណត់។ ប្រសិនបើអាច គ្រូសហគមន៍ត្រូវសរសេរចំណុចសំខាន់ៗសំរាប់បង្រៀន នៅក្នុងវគ្គនីមួយៗ។<br>• ជួយសំរបសំរួលផ្នែកសំភារៈដែលសំខាន់ចាំបាច់ក្នុងការបង្រៀន។ ពិចារណារិះរកមធ្យោបាយផ្សេងៗ ដើម្បីធានាយ៉ាងណាឱ្យមានសំភារៈគ្រប់គ្រាន់សំរាប់ដំណើរការកម្មវិធី។ |
| **ដំណាក់ការទី៧** | **ការរៀបចំកម្មវិធីឡើងវិញ ដើម្បីឱ្យស្របទៅនឹងការឆ្លើយតបរបស់សហគមន៍**<br>• ក្នុងករណីពុំមានអ្នកណាម្នាក់យល់ព្រមក្នុងការបង្រៀនបំណិនមួយចំនួនដែលបានជ្រើសរើសទេ គ្រូបង្រៀនត្រូវឱ្យក្រុមសិស្សទាំងនោះ ទៅរៀនជាមួយក្រុមសិស្សដែលមានជំរើសបំណិនក្នុងក្រុមផ្សេងៗ។ ត្រូវរក្សាចំនួនសមាជិកក្រុមសិស្សមិនឱ្យលើសពី១០នាក់។<br>• ផ្ដល់ពត៌មានដល់ក្រុមនីមួយអំពីគ្រូសហគមន៍ដែលបានយល់ព្រមបង្រៀនដល់ក្រុម |

| | |
|---|---|
| | សិស្ស ។<br>• ពន្យល់ប្រាប់សិស្សអំពីការរៀបចំម៉ោងពេល និងទីកន្លែងសំរាប់ដំណើរការកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ។ |
| **ដំណាក់ការទី៨** | **ការអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន**<br>• ពុំមានកម្មវិធីថ្មីណាអាចដំណើរការបាន ដោយភាពរលូន ដោយពុំមានការផ្លាស់ប្តូរផែនការចាស់នោះឡើយ ។ គ្រូត្រូវធ្វើការត្រួតពិនិត្យរាល់សកម្មភាព និងដោះស្រាយរាល់បញ្ហាដែលកើតឡើង ។ ប្រសិនបើអាច ត្រូវបង្កើតឱ្យមានគណៈកម្មការគ្រូបង្រៀន និងគណៈកម្មការសហគមន៍ ដើម្បីឱ្យទទួលបន្ទុកក្នុងការត្រួតពិនិត្យ និងដោះស្រាយបញ្ហា ។ |
| **ដំណាក់ការទី៩** | **ការវាយតំលៃនៅចុងបញ្ចប់នៃកម្មវិធី (ចុងសប្តាហ៍ទី៨-១២)**<br>• នៅចុងបញ្ចប់នៃកម្មវិធី ត្រូវធ្វើការវាយតំលៃលើជោគជ័យនៃកម្មវិធី ។ រួមជាមួយនឹងគណៈកម្មការកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ត្រូវធ្វើការកត់ត្រា និងបញ្ជាក់ពីអត្ថប្រយោជន៍នៃកម្មវិធី និងបញ្ហានានាដែលកើតឡើងចំពោះកម្មវិធី ។<br>• រិះរកមធ្យោបាយថ្មី ដើម្បីជំរុញ និងកែលំអកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ឱ្យមានលក្ខណៈកាន់ល្អប្រសើរឡើង នៅពេលអនុវត្តនៅជំហានក្រោយទៀត ។ |

## ទំរង់ពាក្យសុំចុះបញ្ជីកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន

**ឈ្មោះកម្មវិធីៈ**

**ឈ្មោះ និងអាសយដ្ឋានរបស់អ្នកផ្តល់សេវាកម្មវិធីបច្ចុប្បន្ន**

១. ឈ្មោះអង្គការៈ ..........................................................................

២. ឈ្មោះអ្នកទំនាក់ទំនងៈ ..........................................................................

៣. ទូរស័ព្ទលេខៈ ..........................................................................

៤. អ៊ីម៉ែលៈ ..........................................................................

**គោលបំណងនៃកម្មវិធីៈ**

១. ..........................................................................

២. ..........................................................................

**វត្ថុបំណងនៃកម្មវិធីៈ**

បំពេញជំរើសមួយ ឬច្រើន នៅក្នុងចន្លោះខាងក្រោមៈ

□ អនុវត្ត និងពង្រីកការសិក្សារបស់សិស្ស ចេញពីកម្មវិធីអប់រំមូលដ្ឋាន (សូមផ្តល់មុខវិជ្ជា និងប្រធានបទ ឬ បំណិនដែលពាក់ព័ន្ធ)ៈ

..........................................................................

..........................................................................

..........................................................................

□ អភិវឌ្ឍបំណិនក្នុងការច្នៃប្រឌិត គិតគូរ ភាពម្ចាស់ការ ស្វ័យសិក្សា ឬ អនុវត្តផ្នែកអក្សរសាស្ត្រ និង លេខនព្វន្ត

(សូមផ្តល់ពត៌មានលំអិត)ៈ ..........................................................................

..........................................................................

..........................................................................

□ អភិវឌ្ឍបំណិនការងារ ដើម្បីពង្រឹង និងលើកស្ទួយជីវភាពគ្រួសារ ឬបំណិនសំរាប់បំរើការងារ (សូមផ្តល់ពត៌មានលំអិត)ៈ

..........................................................................

**គំរិតថ្នាក់**

..................................

..................................

..................................

**រយៈពេលនៃកម្មវិធី**

- ☐ រយៈពេលខ្លី (២-៥ មេរៀន)
- ☐ រយៈពេលមធ្យម (៦-១៥ មេរៀន)
- ☐ រយៈពេលវែង (លើសពី ១៥ មេរៀន)

**ប្រភេទនៃកម្មវិធី**

- ☐ សាកល្បង
- ☐ តែមួយលើក
- ☐ ច្រើនលើក

**បរិយាយកម្មវិធី**

(ផ្តល់សេចក្តីបរិយាយពីសកម្មភាពសិក្សាតាមមេរៀននីមួយៗសំរាប់សិស្ស)

**ទីកន្លែងដំណើរការកម្មវិធី**

(បញ្ជាក់ពីទីកន្លែងដែលកម្មវិធីត្រូវដំណើរការ)

**សំភារៈបង្រៀន**

(ផ្តល់បញ្ជីសំភារៈសំរាប់ដំណើរការកម្មវិធី និងបញ្ជាក់ពីឈ្មោះអ្នកដែលផ្តល់ធនធានសំភារៈទាំងនោះ)

**តំលៃ**

(សូមបញ្ជាក់ពីតំលៃនៃកម្មវិធីដែលពាក់ព័ន្ធនៅក្នុងការផ្តល់សេវាកម្មវិធីនេះ និងចំនួនទឹកប្រាក់គ្រប់គ្រាន់សំរាប់ដំណើរការកម្មវិធី)

**ផលធៀបរវាងសិស្ស និងគ្រូសហគមន៍**

(សូមបញ្ជាក់ពីចំនួនសិស្សអតិបរមា ដែលអាចចូលរួមនៅក្នុងកម្មវិធីនេះ ប្រកបដោយប្រសិទ្ធភាព នៅក្រោមការបង្រៀន និងការត្រួតពិនិត្យរបស់គ្រូសហគមន៍)។

**សៀវភៅគ្រូ ឬ សំភារឧបទេស**

(សូមផ្តល់ពត៌មានលំអិតពីសៀវភៅសំរាប់បង្រៀន ឬសំភារឧបទេស ឬធនធានផ្សេងទៀត ដែលអាចរកបាននៅបច្ចុប្បន្ន ដើម្បីជួយដល់អ្នកផ្តល់សេវាក្នុងការដំណើរការកម្មវិធីនេះ។

**ទីតាំងបច្ចុប្បន្ន**

(សូមផ្តល់ពត៌មានលំអិតអំពីទីកន្លែងផ្តល់កម្មវិធីនេះនៅបច្ចុប្បន្ន)

**ផលធៀបរវាងសិស្ស និងគ្រូសហគមន៍**

(សូមបញ្ជាក់ពីចំនួនសិស្សអតិបរមា ដែលអាចចូលរួមនៅក្នុងកម្មវិធីនេះ ប្រកបដោយប្រសិទ្ធភាព នៅក្រោមការបង្រៀន និងការត្រួតពិនិត្យរបស់គ្រូសហគមន៍)។

**សៀវភៅគ្រូ ឬ សំភារឧបទេស**

(សូមផ្តល់ពត៌មានលំអិតពីសៀវភៅសំរាប់បង្រៀន ឬសំភារឧបទេស ឬធនធានផ្សេងទៀត ដែលអាចរកបាននៅបច្ចុប្បន្ន ដើម្បីជួយដល់អ្នកផ្តល់សេវាក្នុងការដំណើរការកម្មវិធីនេះ។

**ទីតាំងបច្ចុប្បន្ន**

(សូមផ្តល់ពត៌មានលំអិតអំពីទីកន្លែងផ្តល់កម្មវិធីនេះនៅបច្ចុប្បន្ន)

## ឧទាហរណ៍មួយចំនួននៃកម្មវិធីរបស់អង្គការក្រៅរដ្ឋាភិបាល

### អង្គការម្លប់បៃតង

អង្គការម្លប់បៃតង គឺជាអង្គការក្រៅរដ្ឋាភិបាលជាតិមួយ ដែលមានភារកិច្ចបង្កើនការអភិរក្ស និងការយល់ដឹងផ្នែកបរិស្ថាន ។



សកម្មភាពការងារមួយរបស់អង្គការម្លប់បៃតង គឺ *គំរោងបរិស្ថានសាលារៀន*។ គំរោងនេះមានគោលដៅធ្វើអោយប្រសើរឡើងនូវបរិស្ថានតាមសាលារៀន និងគុណភាពនៃការអប់រំតាមរយៈការអប់រំផ្នែកបរិស្ថាន និងបង្កើតការគាំទ្រការអភិរក្សបរិស្ថានក្នុងចំណោមក្មេងៗជំនាន់ក្រោយ ។ ជាផ្នែកមួយនៃ*គំរោងបរិស្ថានសាលារៀន* អង្គការម្លប់បៃតងធ្វើការជាដៃគូជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបង្កើតនិងដំណើរការ "ក្លឹបបរិស្ថាន" សិស្ស ។

*គំរោងបរិស្ថានសាលារៀន* នេះចាប់ដំណើរការនៅក្នុងឆ្នាំ ២០០០ ។ នៅក្នុងឆ្នាំ ២០០៥ នេះអង្គការម្លប់បៃតងកំពុងធ្វើការតាមសាលារៀនចំនួន ៣៣ ក្នុងស្រុក៣ នៃខេត្តកំពង់ស្ពឺ (មានសិស្សសាលាចំនួន១១៩៥នាក់ គ្រូ៦៦នាក់ និងសហគមន៍ សាលារៀន) ។

សកម្មភាពការងាររបស់ "ក្លឹបបរិស្ថាន" ធ្វើឡើងនៅរៀងរាល់ថ្ងៃព្រហស្បតិ៍ នៅតាមសាលានីមួយៗ។ សិស្សចំនួន៣៥ នាក់ត្រូវបានជ្រើសរើសចេញពីថ្នាក់ទី៤-៦ សំរាប់ក្លឹបនីមួយៗ។ សមាជិករបស់ "ក្លឹបបរិស្ថាន" រៀបចំគំរោង និងដំណើរការសកម្មភាពការងារដោយខ្លួនឯង និងដោយមានការណែនាំពីគ្រូបង្រៀន។ (គ្រូនីមួយៗរបស់ក្លិប គឺជាគ្រូស្ម័គ្រចិត្ត ដែលត្រូវបានបណ្តុះបណ្តាលដោយអង្គការម្លប់បៃតង) ។

ឧទាហរណ៍មួយចំនួននៃសកម្មភាពការងាររបស់ក្លិបបរិស្ថានរួមមាន : ការអភិវឌ្ឍគោលនយោបាយកាកសំណល់ នៅក្នុងសាលារៀន ការធ្វើជីកំប៉ុស ការបង្កើតកន្លែងបណ្តុះកូនឈើ និងដាំដើមឈើ ការបង្កើតព្រៃខ្នាតតូចមួយនៅក្នុងទីធ្លាសាលារៀន សកម្មភាពសំអាតសាលារៀន និងធ្វើអោយសាលារៀនមានសោភ័ណភាព ការស្វែងយល់ពត៌មានស្តីពីបរិស្ថាន និងការដឹកនាំសកម្មភាពបរិស្ថាននៅក្នុងសាលារៀន និងសហគមន៍ ។

ក្លិបបរិស្ថានរបស់អង្គការម្លប់បៃតង គឺជាឧទាហរណ៍ដ៏ល្អមួយនៃសកម្មភាពកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ដែលបង្កើតសកម្មភាព ការងារដោយខ្លួនឯង ហើយដែលអាចធ្វើអោយសិស្សានុសិស្សប្រតិបត្តិតាម ដើម្បីជាប្រយោជន៍ដល់សហគមន៍របស់គេ ។

### អង្គការអប់រំពិភពលោក

អង្គការអប់រំពិភពលោក គឺជាអង្គការមួយ ដែលមានគោលបំណងលើកកំពស់ការរស់នៅរបស់ជនក្រីក្រ ឱ្យបានប្រសើរឡើងតាមរយៈការបណ្តុះបណ្តាល និងការផ្តល់ជំនួយផ្នែកបច្ចេកទេស ដល់ការអប់រំទាំងក្នុង និងក្រៅប្រព័ន្ធ ។



អង្គការអប់រំពិភពលោក និងដៃគូរបស់ខ្លួនបានអនុវត្ត **កម្មវិធីវិធានការចំរុះថែទាំដំណាំ** (IPM) នៅតាមសាលាចាប់តាំងពីឆ្នាំ ១៩៩៨មក។ កម្មវិធីនេះមានរយៈពេលពី១៥ ទៅ១៨សប្តាហ៍ នៅតាមថ្នាលពិសោធ-សាលារៀនដែលសិស្សានុសិស្សរៀនពីការដាំស្រូវ ឬបន្លែ ទៅតាមរបៀបមួយដែលមាន លក្ខណៈអេកូឡូស៊ីប្រកបដោយនិរន្តរភាព។ សិស្សអភិវឌ្ឍបំណិនការគិត ពិចារណាល្អិតល្អន់ ទូទៅ និងបំណិនក្នុងការសំរេចចិត្ត តាមរយៈការសិក្សាដកបទពិសោធន៍ជាក់ស្តែង ។

ក្នុងឆ្នាំ២០០៥ នេះ អង្គការអប់រំពិភពលោកកំពុងតែអនុវត្ត **កម្មវិធីវិធានការចំរុះថែទាំ ដំណាំ** ដែលជាគំរោងសាកល្បងឈ្មោះ **"កម្មវិធីសុខភាពបៃតង"** នៅតាមសាលារៀនគោល ដោយចំនួន៦ក្នុងខេត្តព្រៃវែង។ កម្មវិធីសុខភាពបៃតងមានគោលដៅលើកបង្កើនសន្តិសុខ ស្បៀង តាមរយៈការលើកកំពស់អាហារូបត្ថម្ភ និង បច្ចេកទេសដាំបន្លែ (ធ្វើជីកំប៉ុស រៀបចំដី ការដាំ ការថែទាំ និង ការគ្រប់គ្រង សត្វល្អិត ។ល។) ។ គ្រូទទួលការបណ្តុះបណ្តាលជាគ្រូបង្គោលលើដំណាំបន្លែ ដែលមានរយៈពេល២១ថ្ងៃ ដើម្បីទទួលយកចំណេះ ដឹងបច្ចេកទេស និងវិធីសាស្ត្របង្រៀន ដើម្បីបង្រៀនសិស្ស និង ផ្សព្វផ្សាយដល់គ្រូនៅក្នុងកម្រង ជាមួយគ្នា ។

សាលានីមួយៗជ្រើសរើសសិស្សចំនួន៣០នាក់ ដែលស្ម័គ្រ ចិត្តឱ្យចូលរួមរៀនកម្មវិធីសុខភាពបៃតង។ សិស្សភាគច្រើនត្រូវបានជ្រើសរើសចេញពីថ្នាក់ទី ៦ ប៉ុន្តែសាលាខ្លះចំរុះថ្នាក់គ្នា ។ សិស្សរៀបចំដីធ្វើសួនតាមសាលា និង មើលថែរក្សាសួននៅក្នុងសាលារៀន ដើម្បីទុកធ្វើជាសកម្មភាពរៀនរៀងរាល់សប្តាហ៍ ។ បន្ទាប់មកគេធ្វើសួននៅតាមផ្ទះរបស់គេផ្ទាល់ ដើម្បីអនុវត្តជាក់ស្តែងនូវអ្វីដែលគេបានរៀនសូត្រនៅសាលា ។ សិស្សនៅក្នុងកម្មវិធីសុខភាពបៃតង និង គ្រួសារទទួលបានប្រយោជន៍ពីផលបន្លែដែលប្រមូលបានពីសួនទាំងនេះ ។



អង្គការអប់រំពិភពលោកក៏បានអនុវត្ត កម្មវិធី **អុបសិន** នៅក្នុងខេត្តព្រៃវែងផងដែរ ចាប់តាំងពីឆ្នាំ ២០០២មក ។ ផ្នែកមួយនៃកម្មវិធីនេះ គឺជាកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន សំរាប់សិស្សស្រីៗក្នុងថ្នាក់ទី ៥ និង ទី៦ ដែលមានឈ្មោះថា *កម្មវិធីលើកកំពស់កម្មវិធីសិក្សាបំណិនជីវិត* ។

សិស្សនៅក្នុងកម្មវិធីនេះរៀនពី : ការដាំសួ ការយល់ដឹងពីវិជ្ជាជីវៈ IPM (កម្មវិធីវិធានការចំរុះថែទាំដំណាំ) សុខភាព អាហារូបត្ថម្ភ អនាម័យ សុខភាពបន្តពូជ ជំងឺអេដស៍ អំពើហិង្សាក្នុងគ្រួសារ សហគ្រិនភាព ការធ្វើបញ្ជី យេនឌ័រ ការកេងប្រវ័ញ្ច និង ការជួញដូរផ្លូវភេទ។ តាមរយៈសកម្មភាពការងាររបស់កម្មវិធីលើកកំពស់កម្មវិធីសិក្សាបំណិនជីវិតនេះ សិស្សស្រីៗក៏អាចអភិវឌ្ឍបំណិនជីវិតទូទៅ ដូចជា ការជឿជាក់លើខ្លួនឯង បំណិនក្នុងការស្រាវជ្រាវ ការនិយាយជាសាធារណៈ ភាពជាអ្នកដឹកនាំ ការគិតពិចារណា ល្អិតល្អន់ និងការរកដំណោះស្រាយបញ្ហា ។

កម្មវិធីទាំងពីរខាងលើរបស់អង្គការអប់រំពិភពលោក គឺជាឧទាហរណ៍ដ៏ល្អមួយដោយប្រើប្រាស់រយៈពេល ២-៥ ម៉ោង ដែលក្រសួងរៀបចំសំរាប់សកម្មភាព "កម្មវិធីបំណិនជីវិតតាមមូលដ្ឋាន"។ អង្គការក្រៅរដ្ឋាភិបាលបានប្រើម៉ោងសិក្សានេះ ដើម្បីអនុវត្ត

កម្មវិធីរបស់ខ្លួន ដែលឆ្លើយតបទៅនឹងតំរូវការជាក់លាក់របស់សិស្ស ។ សកម្មភាពនេះក៏ជួយពង្រឹងសមត្ថភាពរបស់សាលាក្នុងការគ្រប់គ្រងសកម្មភាពកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន និងបញ្ចូលវិធីសាស្ត្របំណិនជីវិតទៅក្នុងកម្មវិធីសិក្សាទូទៅ របស់សាលា ។

## អង្គការជនពិការអន្តរជាតិ

អង្គការជនពិការអន្តរជាតិ គឺជាអង្គការក្រៅរដ្ឋាភិបាលមួយ ដែលមានភារកិច្ចការពារភាពថ្លៃថ្នូររបស់មនុស្ស និងការពារសិទ្ធិមនុស្ស គាំទ្រដល់ជនពិការគ្រប់រូប និងប្រយុទ្ធប្រឆាំងនឹងបុព្វហេតុដែលបណ្តាលអោយមានពិការភាព ។

កម្ពុជាជាប្រទេសមួយ ដែលមានអត្រាមនុស្សស្លាប់ និងរបួសដោយសារគ្រោះថ្នាក់ចរាចរណ៍ខ្ពស់ ជាពិសេសចំពោះកុមារ ។ អង្គការជនពិការអន្តរជាតិបានចូលរួមក្នុងការអប់រំពីសុវត្ថិភាពចរាចរណ៍ តាំងពីឆ្នាំ២០០៤ មក ។

គំរោងសុវត្ថិភាពចរាចរណ៍របស់អង្គការជនពិការអន្តរជាតិ បានចាប់ផ្តើមដោយមានលក្ខណៈជាគំរោងអភិវឌ្ឍន៍កម្មវិធីសិក្សា ។



អង្គការនេះ បានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីអភិវឌ្ឍកម្មវិធីសិក្សាសុវត្ថិភាពចរាចរណ៍សំរាប់ថ្នាក់ទី១-៦ ។ សព្វថ្ងៃនេះ អង្គការជនពិការអន្តរជាតិ បានធ្វើការសំរបសំរួលកម្មវិធីសិក្សារបស់ខ្លួន អោយត្រូវទៅនឹងបរិបទគោលនយោបាយកម្មវិធីសិក្សាថ្មី ។ ជាផ្នែកមួយនៃកម្មវិធីសិក្សាស្នូលថ្មី សិស្សទាំង អស់នឹងបានរៀនពីមូលដ្ឋានគ្រឹះនៃឥរិយាបថប្រកបដោយសុវត្ថិភាពនៅលើដងផ្លូវ និងក្នុង ការធ្វើចរាចរណ៍ ។ កម្មវិធីសិក្សាអំពីសុវត្ថិភាពចរាចរណ៍ រួមមានប្រធានបទ : ចរិតលក្ខណៈ និងច្បាប់ចរាចរណ៍ ឥរិយាបថ ប្រកបដោយសុវត្ថិភាពរបស់អ្នកថ្មើរជើង អ្នកដំណើរ និងអ្នកបើកបរ និងការធ្វើទស្សនកិច្ចតាមថ្នាក់រៀនរបស់មន្ត្រីនគរបាល និង មន្ត្រីសុខាភិបាល ។

អង្គការជនពិការអន្តរជាតិក៏បានអភិវឌ្ឍមេរៀនស្តីពី កម្មវិធីបំណិនជីវិតតាមមូលដ្ឋាន (រួមមានផែនការបង្រៀន និង ធនធាន) ដែលសាលាអាចប្រើប្រាស់ជាសកម្មភាព កម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ។ មេរៀនទាំងនេះរួមមានសកម្មភាពមួយចំនួន ដូចជាការស្ថាបនាផ្លូវសិប្បនិម្មិត សំរាប់អោយសិស្សប្រើប្រាស់ក្នុងការសំដែងអំពីការប្រើប្រាស់ផ្លូវថ្នល់ និងការណែនាំពីរបៀបអញ្ជើញអ្នកឧទ្ទេសមកថ្នាក់រៀន ។

ប្រការដែលអង្គការជនពិការអន្តរជាតិ ធ្វើការសំរបសំរួលកម្មវិធីសិក្សារបស់ខ្លួន អោយត្រូវនឹងបរិបទគោលនយោបាយកម្មវិធីសិក្សាថ្មី គឺជាឧទាហរណ៍ដ៏ល្អមួយដែលអង្គការក្រៅរដ្ឋាភិបាលអាចផ្តល់នូវគំនិត និងធនធានសំរាប់អោយសាលារៀនប្រើប្រាស់ក្នុងការអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋានរបស់ខ្លួន ។